នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Sep-2019,09:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើបន្ទាន់ទាក់ទងនឹងផលប៉ះពាល់លើកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខនៃមរណភាពរបស់ នួន ជា មុនពេលចេញសាលដីកាបណ្ដឹងសាទុក្ខ (F46/2)**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS
(បម្រុង)

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ

**ជនជាប់ចោទ:**
ខៀវ សំផន

**មេធាវីការពារក្តី ខៀវ សំផន**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**មេធាវីការពារក្តី នួន ជា**
លោក សុន អរុណ
លោក លីវ សុវណ្ណា
លោកស្រី Doreen CHEN

## I. សេចក្ដីផ្ដើម

1. អំណះអំណាងរបស់ក្រុមមេធាវីការពារក្ដី នួន ជា ដែលថា ដោយសារតែមរណភាពរបស់ នួន ជា ក្នុងអំឡុងពេលកំពុងរង់ចាំបណ្ដឹងសាទុក្ខរបស់គាត់ ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង០០២/០២ នេះ៖ (i) សច្ចធារណ៍នៃនិរទោសបន្តអនុវត្តលើគាត់ (ii) ការផ្ដន្ទាទោសរបស់គាត់គួរត្រូវបានទុកជាមោឃៈ[1] អំណះអំណាងទាំងពីរនេះមិនមានអង្គសេចក្ដីទេ។ ទោះបីជាការបន្តអនុវត្តសច្ចធារណ៍នៃនិរទោសលើបណ្ដឹងសាទុក្ខស្របគ្នាទៅនឹងការអនុវត្តរបស់កម្ពុជាក្ដី ក៏វាមិនស៊ីចង្វាក់គ្នាជាមួយនឹងការអនុវត្ត និងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ និងតុលាការអន្តរជាតូបនីយកម្មនានា ដែលស្រដៀងគ្នាខ្លាំងទៅនឹង អ.វ.ត.ក ទាក់ទងនឹងរចនាសម្ព័ន្ធ និងអាណត្តិ ហើយដែលហេតុដូច្នេះ ផ្ដល់នូវការណែនាំដ៏ល្អបំផុតចំពោះវិធីសាស្ត្រសមស្របនៅ អ.វ.ត.ក នេះ។ ទោះជាយ៉ាងណា ការអះអាងរបស់មេធាវីការពារក្ដីដែលថា ការរំលត់នីតិវិធី បានធ្វើឲ្យការផ្ដន្ទាទោសប្រឆាំងនឹង នួន ជា ទៅជាមោឃៈនោះ មិនមានមូលដ្ឋានផ្លូវច្បាប់នៅក្នុងការអនុវត្តជាអន្តរជាតិ ឬការអនុវត្តរបស់កម្ពុជានោះឡើយ។

2. សហព្រះរាជអាជ្ញាដាក់ចម្លើយតបនេះជាភាសាអង់គ្លេសជាមុនសិន ដោយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយត្រឹមថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩[2]។

## II. សច្ចធារណ៍នៃនិរទោសនៅ អ.វ.ត.ក មិនលាតសន្ធឹងដល់កិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខទេ

---

[1] ឯកសារ **F46/2** សំណើបន្ទាន់ ទាក់ទងនឹងផលប៉ះពាល់លើនីតិវិធីបណ្ដឹងសាទុក្ខនៃការទទួលមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៩ (“សំណើ”) កថាខណ្ឌ ១(ខ)(i), ២២-២៣, ២៩(ខ), ៣២-៣៤, ៨៩(ខ)(i) *និង* ផ្នែកទី ៤ ចំណងជើងទី II។ ក.ស.ព បានឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្ដីសុំឲ្យបន្តរក្សាទុក (ឯកសារ **F46/2** សំណើ កថាខណ្ឌ ១(ឃ)(ii), ៨៧-៨៨, ៨៩(ឃ)(ii)) ក្នុងឯកសារ **F46/4/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើបន្ទាន់ដើម្បីតែងតាំងក្រុមមេធាវីការពារក្ដី នួន ជា ឡើងវិញ ចុះថ្ងៃទី២២ ខែសីហា ឆ្នា២០១៩។ ទាក់ទងនឹងសំណើរបស់មេធាវីការពារក្ដីអំពីវិសោធនកម្មវិធានផ្ទៃក្នុង ស.ព.អ សង្កេតឃើញថា តាមវិធានផ្ទៃក្នុង អ.ជ.ត.ក ដំបូងត្រូវតែសម្រេចលើបញ្ហានេះមុនពេលតម្រូវការស្នើសុំឲ្យមានវិសោធនកម្មនេះត្រូវបានស្នើឡើង។ *សូមមើល* អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មទី៩) ដូចដែលត្រូវបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ (“វិធានផ្ទៃក្នុង”) វិធាន ២។

[2] ឯកសារ **F46/2/2** សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់ចម្លើយរបស់ខ្លួនតបទៅនឹងសំណើបន្ទាន់របស់ក្រុមមេធាវីការពារក្ដី នួន ជា ជាភាសាអង់គ្លេសជាមុនសិន, ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩។ ឯកសារ **F46/2/3** សេចក្ដីសម្រេចស្ដីពីសំណើរជាបន្ទាន់របស់សហព្រះរាជអាជ្ញាដើម្បីដាក់ចម្លើយតបទៅនឹងសំណើជាបន្ទាន់របស់មេធាវីការពារក្ដី នួន ជា ក្នុងការដាក់ឯកសារមួយភាសា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ កថាខណ្ឌ៩។

## *(1) វិសាលភាពនៃសច្ចធារណ៍នៃនិរទោសដែលអះអាងដោយមេធាវីការពារក្តីមិនស្របគ្នាទៅនឹងការអនុវត្តជាអន្តរជាតិទេ*

3. ទោះបីជាច្បាប់ប្រទេសកម្ពុជាចែងសម្រាប់សច្ចធារណ៍នៃនិរទោស មានរហូតទាល់តែសាលក្រមស្ថាពរ[3] ក៏ដោយ "វចនាសម្ព័ន្ធរបស់ អ.វ.ត.ក ខុសប្លែកពីប្រព័ន្ធតុលាការកម្ពុជា"[4] ដោយសារតែ "អាណត្តិជាក់លាក់របស់ អ.វ.ត.ក ព្រមទាំងច្បាប់កម្ពុជាផង"[5]។ ហេតុដូច្នេះ ជនជាប់ចោទត្រូវបានសន្មតថាគ្មានទោសនៅ អ.វ.ត.ក តែត្រឹមពេលដែលពិរុទ្ធភាពរបស់ខ្លួនត្រូវបានបង្ហាញហួសពីវិមតិសង្ស័យដោយចៅក្រមតែប៉ុណ្ណោះ[6]។ អភិក្រមនេះ មិនធ្វើឱ្យប៉ះពាល់ដល់ខ្លឹមសារសំខាន់នៃរដ្ឋធម្មនុញ្ញកម្ពុជាទេ ហើយក៏មិនប៉ះពាល់ដល់ការបកស្រាយដែរ។ ផ្ទុយទៅវិញ អភិក្រមនេះទទួលស្គាល់ភាពខុសគ្នាដែលមានមករវាងប្រព័ន្ធច្បាប់ អវតក និងច្បាប់កម្ពុជា។

4. ផ្ទុយទៅនឹងអំណះអំណាងរបស់មេធាវីការពារក្តីរបស់ នួន ជា[7] មាត្រា ៣៥ និង ៣៧ នៃច្បាប់ អ.វ.ត.ក មិនស៊ីចង្វាក់គ្នាទៅនឹងនីតិវិធី និងការអនុវត្តដែលពាក់ព័ន្ធនៅកម្រិតអន្តរជាតិទេ។ ដូចមានចែងនៅក្នុងមាត្រា ១២ នៃកិច្ចព្រមព្រៀង និងមាត្រា ៣៣ នៃច្បាប់ អ.វ.ត.ក នៅពេលដែលមានចម្ងល់ទាក់ទងនឹងភាពស៊ីចង្វាក់គ្នានៃវិធានណាមួយជាមួយនឹងបទដ្ឋានអន្តរជាតិ "គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"[8]។

5. អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ចំណុចនេះ នៅពេលដែលខ្លួនបានសម្រេចថា ខ្លួនត្រូវបាន "អនុញ្ញាតដោយកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក្នុងការស្វែងរកសេចក្តីណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតក្នុងកម្រិត

---

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា ៣៨ ("ជនជាប់ចោទត្រូវចាត់ទុកថាគ្មានទោស ដរាបណាតុលាការមិនទាន់សម្រេចសេចក្តីស្ថាពរ")។

[4] ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ("សាលដីកាសំណុំរឿង០០២/០១") កថាខណ្ឌ ១០៧។

[5] សំណុំរឿង០០១-**F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីកា *ឌុច*") កថាខណ្ឌ ៣៤៨។

[6] *សូមមើល* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង") មាត្រា ១៣(១)។ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។

[7] ឯកសារ **F46/2** សំណើ កថាខណ្ឌ២២។

[8] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលប្រកាសឱ្យប្រើ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៣ថ្មី។

អន្តរជាតិ នូវការបកស្រាយដោយស្ថាប័នតុលាការអន្តរជាតិ"[9]។ ផ្អែកលើមូលដ្ឋាននេះ អ.ជ.ត.ក បានសន្និដ្ឋានថា "យុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR ត្រូវបានយកមកប្រើប្រាស់ជាប្រភពនៃសេចក្តីណែនាំនៅក្នុងការបកស្រាយវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង [យុត្តាធិការរបស់ អ.ជ.ត.ក]"[10]។

6. អ.វ.ត.ក ដូចគ្នានឹងតុលាការ ICTY និង ICTR ព្រមទាំងតុលាការអន្តរជាតិ និងតុលាការអន្តរជាតូបនីយកម្មផ្សេងៗទៀតដែរ ត្រូវបានបង្កើតឡើងជាពិសេស ដើម្បីដោះស្រាយអំពីអំពើឃោរឃៅទ្រង់ទ្រាយធំ ដែលបណ្តាលឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិ ដែលមិនអាចត្រូវបានកាត់ទោសដោយយុត្តាធិការក្នុងស្រុក ដោយសារតែភាពធ្ងន់ធ្ងរ និងភាពធំធេងរបស់វាបានទេ។ ជាក់ស្តែង វចនាសម្ព័ន្ធបណ្តឹងសាទុក្ខនៅ អ.វ.ត.ក[11] ឆ្លុះបញ្ចាំងឱ្យឃើញយុត្តាធិការរបស់តុលាការ ICTY, ICTR, ICC និង SCSL ដោយមានតែការពិនិត្យលើបណ្តឹងសាទុក្ខតែមួយថ្នាក់ប៉ុណ្ណោះចំពោះសាលក្រមសាលាដំបូង[12]។ បទដ្ឋាននៃការពិនិត្យឡើងវិញនៅតុលាការទាំងនេះ លើកលែងតែតុលាការ ICC[13] ក៏ដូចគ្នាផងដែរទៅនឹង អ.វ.ត.ក ដោយពិនិត្យតែកំហុសនីតិវិធី កំហុសអង្គច្បាប់ ដែលធ្វើឱ្យសេចក្តីសម្រេចទៅជាមោឃៈ ឬកំហុសអង្គហេតុ ដែលនាំឱ្យមានភាពអយុត្តិធម៌[14] ដែល

[9] សំណុំរឿង០០១-**F28** សាលដីកា *ខុច*, កថាខណ្ឌ ១៣។

[10] សំណុំរឿង០០១-**F28** សាលដីកា *ខុច* កថាខណ្ឌ ១៣។

[11] សូមមើល ការពន្យល់របស់ អ.ជ.ត.ក អំពីការពនិត្យលើបណ្តឹងសាទុក្ខដែលត្រូវបានកំណត់នៅ អ.វ.ត.ក ធៀបទៅនឹងប្រព័ន្ធដែលអនុញ្ញាតឱ្យការពិនិត្យ *ជាថ្មីឡើងវិញ* លើបណ្តឹងសាទុក្ខ ឯកសារ **F36** សំណុំរឿង០០២/០១ សាលដីកា កថាខណ្ឌ៨៣-៨៥។

[12] **ICTY:** លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ ដូចដែលត្រូវបានធ្វើធ្វើបច្ចុប្បន្នភាពក្នុងខែកញ្ញា ឆ្នាំ២០០៩ ("លក្ខន្តិកៈ ICTY") មាត្រា ១១(ក)។ **ICTR**: លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដូចដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤ ("លក្ខន្តិកៈ ICTR") មាត្រា ១០(ក)។ **ICC**: លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ("លក្ខន្តិកៈក្រុងរ៉ូម") 2187 UNTS 90, មាត្រា ៣៩(ខ)។ **SCSL**: លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ត្រូវបានភ្ជាប់ជាឧបសម្ពន្ធទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលប្រទេសសៀរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន, Freetown, ថ្ងៃទី១៦ ខែមករា ឆ្នាំ២០០២ ("លក្ខន្តិកៈ SCSL"), 2178 UNTS 137, មាត្រា ១១(ក)។

[13] **ICC**: មាត្រា ៨១(១)(ក)-(ខ) នៃលក្ខន្តិកៈក្រុងរ៉ូម។

[14] **ICTY**: មាត្រា ២៥(១)(ក)-(ខ) នៃលក្ខន្តិកៈតុលាការ ICTY។ **ICTR**: មាត្រា ២៤(១)(ក)-(ខ) នៃលក្ខន្តិកៈតុលាការ ICTR។ **SCSL**: មាត្រា ២០(១) នៃលក្ខន្តិកៈតុលាការ SCSL។

អង្គជំនុំជម្រះតុលាការកំពូលគោរពតាមចៅក្រមក្នុងការវាយតម្លៃរបស់ខ្លួនលើភស្តុតាង និងសម្អាងហេតុ[15]។

7. ដោយសារតែអាណត្តិ វចនាសម្ព័ន្ធ និងគោលដៅស្រដៀងគ្នា ការអនុវត្តដែលត្រូវបានអនុម័តយកដោយតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀត ទាក់ទងទៅនឹងវិសាលភាពនៃសច្ចធារណ៍នៃនិរទោសលើបណ្តឹងសាទុក្ខ ពាក់ព័ន្ធជាពិសេសទៅនឹង អ.វ.ត.ក[16]។

---

[15] **ICTY**: *រដ្ឋអាជ្ញា ទល់នឹង Karadžić*, MICT-13-55-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ ១៧ ("ក្នុងការសម្រេចថាតើ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងត្រឹមត្រូវ ឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនត្រូវបដិសេធស្រាលៗនូវការរកឃើញផ្អែកអង្គហេតុនានាដែលត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងទេ") *សូមមើលផងដែរ* កថាខណ្ឌ ១៨, ៣២១, ៣២៣, ៣៦៣។ **ICTR**: *រដ្ឋអាជ្ញា ទល់នឹង Nyiramasuhuko និងគូកន*, ICTR-98-42-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ៣២ ("ទាក់ទងនឹងកំហុសអង្គហេតុ វាបង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនត្រូវបដិសេធស្រាលៗនូវការរកឃើញអង្គហេតុដែលត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងនោះទេ")។ **SCSL**: *រដ្ឋអាជ្ញា ទល់នឹង Taylor*, SCSL-03-01-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ កថាខណ្ឌ ២៦ ("ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងនឹងមិនត្រូវបដិសេធសើៗនោះទេ ដោយសារតែអង្គជំនុំជម្រះសាលាដំបូង ត្រូវជាពិសេសវាយតម្លៃភស្តុតាងដែលទទួលបាននៅសវនាការ")។

[16] *ផ្ទុយទៅនឹង* ឯកសារ **F46/2** សំណើ កថាខណ្ឌ ៣៥-៤៧។ នៅកម្រិតថ្នាក់ជាតិ រយៈពេលនៃសច្ចធារណ៍នៃនិរទោសគឺច្របូកច្របល់។ យុត្តាធិការរបស់ប្រព័ន្ធច្បាប់ស៊ីវិលខ្លះ បន្តសច្ចធារណ៍នេះរហូតដល់ពេលមានសាលដីកាស្ថាពររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ (សូមមើលឧទាហរណ៍ *Delić* សេចក្តីសម្រេច កថាខណ្ឌ១១) ចំណែកឯនៅក្នុងប្រទេស ខំមិនឡូជាច្រើនទៀត សច្ចធារណ៍នេះត្រូវបានបញ្ចប់នៅពេលមានការផ្តន្ទាទោសនៅដំណាក់កាលសវនាការ។ ឧទាហរណ៍ នៅក្នុងប្រទេស**កាណាដា** ឧក្រិដ្ឋជនដែលបានផ្តន្ទាទោស ត្រូវតែបង្ហាញកំហុសដែលតម្រូវឱ្យ ការផ្តន្ទាទោសត្រូវបានទុកជាមោឃៈ ដោយហេតុថាសច្ចធារណ៍នៃនិរទោស មិនធ្វើឱ្យការផ្តន្ទាទោសរស់ឡើងវិញនោះទេ (*សូមមើល R. ទល់នឹង Smith* [2004] 1 S.C.R. 385, 2004 SCC 14, កថាខណ្ឌ ១៦)។ ក្នុងប្រទេស**ឥណ្ឌា** នៅពេលដែលតុលាការថ្នាក់ទាបផ្តន្ទាទោសជនជាប់ចោទ និងកាត់ទោស សច្ចធារណ៍នៃនិរទោសត្រូវចប់។ (*សូមមើល B.R. Kapur ទល់នឹង រដ្ឋ Tamil Nadu និង Ors* (២០០១) 7 SCC 231, កថាខណ្ឌ៤០។ *Shamsher Singh alias Shera ទល់នឹង រដ្ឋ Haryana* (២០០២) 7 SCC 536, កថាខណ្ឌ៧)។ ក្នុងប្រទេស**កេនយ៉ា** ការជំទាស់ទៅនឹងសាលក្រមរបស់តុលាការជំនុំជម្រះមិនធ្វើឱ្យកើតមានឡើងវិញនូវ សច្ចធារណ៍នៃនិរទោសឡើយ ហើយការផ្តន្ទាទោសនៅតែមានដដែល រហូតទាល់តែត្រូវបានបដិសេធនៅដំណាក់កាលសាទុក្ខ (*សូមមើល Kigoro Machoro ទល់នឹង Republic* [២០១៩], eKLR, កថាខណ្ឌ១៧។ *Bernard Simiyu Wawire ទល់នឹង Republic* [២០១៦] eKLR, កថាខណ្ឌ ១១)។ នៅប្រទេសផ្សេងៗទៀត បន្ថយនីតិវិធីលើបណ្តឹងសាទុក្ខ និងរក្សាទុកការផ្តន្ទាទោសឱ្យនៅដដែលនៅពេលអ្នកប្តឹងសាទុក្ខទទួលមរណភាព ដោយបញ្ជាក់ថា សច្ចធារណ៍នៃនិរទោសមិនអនុវត្តបានទេក្រោយការផ្តន្ទាទោស។ *សូមមើលឧទាហរណ៍ផងដែរ* នៅ**ប្រទេសអូស្ត្រាលី** *R. v. Rimon* [2003] VSCA 136, 6 VR 553, 142 A Crim R 226, paras 1, 4-6; *Quartermaine v. The Queen* [2002] WASCA 345, paras 3-5; *Sen v. The Queen* [1991] 55 A Crim R 349, paras 11, 14-15; **ចក្រភពអង់គ្លេស:** *R. v. Kearley* (No. 2) [1994] 2 AC 414, 420-423; *R. v. Jefferies* [1969] 1 Q.B. 120, 123-125.។

8. យុត្តិសាស្ត្រពីតុលាការដែលស្រដៀងគ្នាបំផុតជាមួយនឹង អ.វ.ត.ក ក្នុងរចនាសម្ព័ន្ធ និងគោលបំណង បង្ហាញថា សច្ចធារណ៍នៃនិរទោសគួរបញ្ចប់ដោយសាលក្រមសាលាដំបូង[17]។ ក្នុងឆ្នាំ២០១០ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសន្និដ្ឋានថា "ការណ៍ដែលសច្ចធារណ៍នៃនិរទោសមិនអនុវត្តលើជនដែលត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះសាលាដំបូង ដែលរង់ចាំសេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់គេ"[18]។ ការណ៍នេះ "ស្របគ្នាទៅនឹងបទដ្ឋាននៃការពិនិត្យឡើងវិញ ដែល

---

[17] មានតែតុលាការ ពាក់ព័ន្ធជាមួយនឹងស្ថានភាពពិសេសរបស់បុគ្គលម្នាក់ដែលត្រូវបានផ្តន្ទាទោសនៅពេលសវនាការ ទទួលមរណភាពនៅក្នុងអំឡុងរង់ចាំសេចក្តីសម្រេចពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍។ ទោះបីយ៉ាងណាក៏ដោយ សេចក្តីសម្រេចរបស់តុលាការ **ICTR, ICC** និង **SCSL** ផ្តល់ការគាំទ្រចំពោះគោលការណ៍ដែលថា សច្ចធារណ៍នៃនិរទោសឈប់អនុវត្ត នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងចេញការផ្តន្ទាទោស។ *សូមមើលឧទាហរណ៍* **ICC:** *រដ្ឋអាជ្ញា ទល់នឹង Lubanga*, ICC-01/04-01/06, អង្គជំនុំជម្រះសាលាដំបូង សាលក្រម អនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ កថាខណ្ឌ ៩២ ("តាមមាត្រា ៦៦ នៃលក្ខន្តិកៈ [ក្រុងរ៉ូម] ជនជាប់ចោទត្រូវបានសន្មតថាគ្មានទោសរហូតទាល់តែរដ្ឋអាជ្ញាបានបង្ហាញពីពិរុទ្ធភាពរបស់គាត់។ ចំពោះការផ្តន្ទាទោសវិញ ធាតុផ្សំនីមួយៗ នៃបទល្មើសជាក់លាក់ណាមួយដែលត្រូវបានចោទប្រកាន់ ត្រូវតែបង្ហាញ "ឲ្យហួសពីវិមតិសង្ស័យ"")។ *រដ្ឋអាជ្ញា ទល់នឹង Ngudjolo*, ICC-01/04-02/12, អង្គជំនុំជម្រះសាលាដំបូង សាក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៣៤។ *រដ្ឋអាជ្ញា ទល់នឹង Kayishema & Ruzindana*, ICTR-95-1-A, អង្គជំនុំជម្រះសាលាឧទ្ធរណ សាលដីកា (សម្អាងហេតុ) ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ១០៧ ("ស្របគ្នាទៅនឹងគោលការណ៍នៃសច្ចធារណ៍នៃនិរទោស [...] វាគឺជាកាតព្វកិច្ចរបស់រដ្ឋអាជ្ញាក្នុងការបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទឲ្យហួសពីវិមតិសង្ស័យ")។ **ICTR:** *Rutaganda ទល់នឹង រដ្ឋអាជ្ញា*, ICTR-96-3-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ១៧២ ("បទដ្ឋាននៃការបង្ហាញភស្តុតាងត្រូវអនុវត្តនោះគឺថា ការបង្ហាញភស្តុតាងហួសពីវិមតិសង្ស័យ និង [...] បន្ទុកភស្តុតាងជារបស់អយ្យការ [...] ដោយសារតែជនជាប់ចោទទទួលបានអត្ថប្រយោជន៍នៃសច្ចធារណ៍នៃនិរទោស")។ **SCSL:** *រដ្ឋអាជ្ញា ទល់នឹង Sesay និងគូកន* SCSL-04-15-T, អង្គជំនុំជម្រះសាលាដំបូង សាលក្រម ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ៤៧៥ ("មាត្រា ១៧(៣) នៃលក្ខន្តិកៈ តុលាការ [SCSL] តម្កល់គោលការណ៍ដែលថា ជនជាប់ចោទត្រូវបានសន្មត់ថាគ្មានទោសរហូតទាល់តែត្រូវបានបញ្ជាក់ថាមានពិរុទ្ធភាព។ មានតែភាគីអយ្យការតែឯងប៉ុណ្ណោះដែលមានបន្ទុកក្នុងការបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ អង្គហេតុនីមួយៗ ដែលការផ្តន្ទាទោសផ្អែកលើត្រូវតែបញ្ជាក់ឲ្យហួសពីវិមតិសង្ស័យ")។

[18] *រដ្ឋអាជ្ញា ទល់នឹង Delić* សំណុំរឿងលេខ IT-04-83-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សេចក្តីសម្រេចលើលទ្ធផលនៃកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១០ ("សេចក្តីសម្រេចលើករណីរបស់ *Delić*") កថាខណ្ឌ ១៤។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Milutinović និងគូកន* សំណុំរឿងលេខ IT-05-87-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សំណៅកោសលុបសាធារណៈនៃ "សេចក្តីសម្រេចលើសំណើសុំលើកទីពីររបស់ Vladimir Lazarević ស្តីពីការដោះលែងជាបណ្តោះអាសន្ននៅលើទឡ្ហីករណ៍នៃសេចក្តី មេត្តា" ដែលបានចេញនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ ៩។ *រដ្ឋអាជ្ញា ទល់នឹង Popović និងគូកន.*, IT-05-88-AR65.8, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចលើញត្តិរបស់ Gvero ស្នើសុំការដោះលែងបណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ កថាខណ្ឌ ១១ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ពន្យល់ពីភាពផ្សេងគ្នារវាងការដោះលែងបណ្តោះអាសន្ន ក្នុងពេលជំនុំជម្រះ

អាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ដែលភាគីដាក់បណ្តឹងសាទុក្ខមានបន្ទុកក្នុងការបង្ហាញអំពីកំហុសអង្គច្បាប់ ឬអង្គហេតុ ដែលធ្វើឱ្យមោឃៈសាលក្រមសាលាដំបូង ឬដែលនាំឱ្យមានភាពអយុត្តិធម៌ មិនមែនប៉ុនប៉ងផ្តួចផ្តើមឱ្យមានការជំនុំជម្រះ*ជាថ្មី*នោះទេ"[19]។ អង្គជំនុំជម្រះនេះបានគូសបញ្ជាក់ថា "បន្ទុកនេះគឺខុសគ្នាទាំងស្រុងពីបន្ទុកដែលដំណើរការនៅពេលជំនុំជម្រះដែលសច្ចធារណ៍នៃនិរទោសត្រូវតែអនុវត្ត ហើយអយ្យការត្រូវបង្ហាញរឿងក្តីរបស់ខ្លួនឱ្យហួសពីវិមតិសង្ស័យ"[20]។

9. ក្នុងឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានអះអាងចំពោះគោលការណ៍នេះថា សច្ចធារណ៍នៃនិរទោស មិនបន្តទៅលើបណ្តឹងសាទុក្ខប្រឆាំងនឹងការកាត់ទោសណាមួយទេ[21]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា "ដោយបានរកឃើញថា មរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខជាលទ្ធផលបញ្ចប់ដល់កិច្ចដំណើរការនីតិវិធី និងដោយសារមិនទាន់មានសាលដីកាត្រូវបានចេញទាក់ទងនឹង Gvero នោះគ្មានអ្វីដែលអាចធ្វើឱ្យខូចដល់ភាពស្ថាពរនៃសាលក្រមសាលាដំបូងបានទេ ទាក់ទងនឹង Gvero[22]។ ទាំង Delić និងទាំង Gvero សុទ្ធតែបានដាក់សារណាបណ្តឹងសាទុក្ខរបស់ពួកគេរៀងៗខ្លួន ហើយនៅពេលពួកគេស្លាប់[23]។ យ៉ាងណាមិញ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ដោយបានប្រកាសថា សច្ចធារណ៍នៃនិរទោស លែងអនុវត្តបានទៀតហើយ ដោយសារមានការកាត់ទោសនៅពេលសវនាការរួចហើយ និងបានប្រកាសថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង គឺស្ថាពរហើយ[24]។

---

និងក្នុងពេលសាទុក្ខ ដោយប្រៀបធៀបសេចក្តីសម្រេចមួយ "ទាក់ទងទៅនឹងជនម្នាក់ដែលត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះសាលាដំបូង និងដែលរឿងក្តីរបស់ខ្លួនកំពុងស្ថិតនៅដំណាក់កាលសាទុក្ខ" និង "ជនជាប់ចោទម្នាក់កំពុងស្ថិតនៅដំណាក់កាលជំនុំជម្រះ ដែលនៅទទួលបានអត្ថប្រយោជន៍ពីសច្ចធារណ៍នៃនិរទោសនៅឡើយ")។

[19] *Delić* សេចក្តីសម្រេច កថាខណ្ឌ ១៤។

[20] *Delić* សេចក្តីសម្រេច កថាខណ្ឌ ១៤។

[21] *រដ្ឋអាជ្ញា ទល់នឹង* Popović *នឹងគូកន.*, IT-05-88-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកាសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខទាក់ទងនឹង Milan Gvero ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៣ ("សាលដីកាសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី *Popović*") កថាខណ្ឌ ៥-៧។

[22] សាលដីកាសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី *Popović* កថាខណ្ឌ ៦។

[23] សាលដីកាសម្រេចក្នុងរឿងក្តី *Delić* កថាខណ្ឌ ១។ សាលដីកាសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី *Popović* កថាខណ្ឌ ១។

[24] សាលដីកាសម្រេចក្នុងរឿងក្តី *Delić* កថាខណ្ឌ ១៤-១៦។ សាលដីកាសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី *Popović* កថាខណ្ឌ ៥-៦។

10. ការអនុវត្តវិធីសាស្ត្រនេះនៅ អ.វ.ត.ក ត្រូវបានគាំទ្រដោយកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀង អ.វ.ត.ក និងសម្រេចបាននូវដំណោះស្រាយបញ្ហាប្រកបដោយសមធម៌ជាង។ គោលបំណងនៃកិច្ចព្រមព្រៀងនេះ ដែលជាសន្ធិសញ្ញាអន្តរជាតិមួយដែលបង្កើតបានជាផ្នែកមួយនៃច្បាប់កម្ពុជា[25] គឺត្រូវនាំយកពួកមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានារបស់ខ្មែរក្រហម ឲ្យទទួលខុសត្រូវទៅតាមច្បាប់[26]។ វាក៏បានទទួលស្គាល់យ៉ាងច្បាស់លាស់ផងដែរនូវ "កង្វល់ស្របច្បាប់របស់ [...] ប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌"[27]។

11. ការទទួលស្គាល់ពីផលប្រយោជន៍យុត្តិធម៌របស់ប្រជាជនកម្ពុជានេះ ឆ្លុះបញ្ចាំងអង្គហេតុដែលថា សិទ្ធិក្នុងការទទួលបានយុត្តិធម៌របស់ជនរងគ្រោះ ត្រូវបានតម្កល់ទុកនៅក្នុងច្បាប់អន្តរជាតិ[28]។ គោលការណ៍ជាមូលដ្ឋាន និងគោលការណែនាំរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិរបស់ជនរងគ្រោះ[29] ចែង *ជាអាទិ៍* ថា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សត្រូវបានស៊ើបអង្កេត ត្រូវបានចោទប្រកាន់ និងត្រូវបានផ្ដន្ទាទោស[30] ការទទួលស្គាល់ពីការធ្វើឲ្យរងគ្រោះ និងការបង្ហាញជាសាធារណៈអំពីព្យសនកម្មដែលបានទទួលរង[31] និងការដឹងពីសច្ចភាពពេញលេញ និងទាំងស្រុង ទាក់

[25] *សូមមើល* កិច្ចព្រមព្រៀង, មាត្រា ៣១ ("កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តដូចជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោយពីទទួលសច្ចាប័ន [...]")។ *សូមមើល* ផងដែរ ច្បាប់ អ.វ.ត.ក មាត្រា ៤៧*ស្ទួន*ថ្មី។

[26] *សូមមើល* កិច្ចព្រមព្រៀង, មាត្រា ១។

[27] កិច្ចព្រមព្រៀង, បុព្វកថា។

[28] *សូមមើល* កតិការសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ទីក្រុងញូយ៉ក ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ("ICCPR") 999 UNTS 171 មាត្រា ២(៣)(ក) (តម្រូវឲ្យរដ្ឋភាគីឲ្យ "ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួនដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឲ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ")។ សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ សេចក្ដីសម្រេចរបស់មហាសន្និបាតលេខ ២១៧ (III) UN Doc. A/810 មាត្រា ៨ "មនុស្សគ្រប់រូបមានសិទ្ធិរកដំណោះស្រាយស័ក្តិសិទ្ធិមួយនៅចំពោះមុខសាលាជំរះក្ដីជាតិ ដែលមានសមត្ថកិច្ចចំពោះអំពើទាំងឡាយណាដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួន ដែលត្រូវបានទទួលស្គាល់ ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់"។ អនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម និងអំពើឃោរឃៅផ្សេងៗទៀត ការធ្វើបាប ឬបន្ថោកបន្ទាបបែបអមនុស្សធម៌ និងការផ្ដន្ទាទោស 1465 UNTS 113, New York, ចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧ មាត្រា១៤ (១)។

[29] គោលការណ៍មូលដ្ឋាន និង សេចក្ដីណែនាំស្ដីពីសិទ្ធិក្នុងការទទួលបាននូវដំណោះស្រាយ និងសំណងចំពោះជនរងគ្រោះពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ, UN Doc. A/RES/60/147 (ឆ្នាំ ២០០៥) ("គោលការណ៍ជាមូលដ្ឋានរបស់ អ.ស.ប")។

[30] គោលការណ៍ជាមូលដ្ឋានរបស់ អ.ស.ប, កថាខណ្ឌ ៤។

[31] គោលការណ៍ជាមូលដ្ឋានរបស់ អ.ស.ប, កថាខណ្ឌ ២៤។ *សូមមើលផងដែរ* Brianne McGonigle Leyh, យុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី? ការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី អន្តរជាតិ (ឆ្នាំ ២០១១) ទំព័រ ១០២។

ទងទៅនឹងព្រឹត្តិការណ៍ដែលបានកើតឡើង អ្នកដែលបានចូលរួមចំណែកនៅក្នុងនោះ ព្រមទាំងមូលហេតុដែលបានកើតឡើង[32]។

12. ការសម្រេចដែលថា នួន ជា ត្រូវបានបន្តសន្មតថាគ្មានទោស ទោះបីជាមានការផ្តន្ទាទោសហួសពីវិមតិសង្ស័យនៅក្នុងការជំនុំជម្រះមួយ ដែលបានប្រព្រឹត្តទៅដោយការការពារកិច្ចដំណើរការនីតិវិធីទាំងអស់ និងការគោរពទាំងស្រុងនូវសិទ្ធិរបស់ជនជាប់ចោទនោះ មិនអាចធ្វើឱ្យអន្តរាយដល់កិច្ចការរបស់ អ.វ.ត.ក ក្នុងការធានានូវសិទ្ធិទាំងអស់នេះរបស់ជនរងគ្រោះបានឡើយ។ សច្ចភាពទាំងស្រុង និងពេញលេញស្តីពីការធ្វើឱ្យរងគ្រោះ មូលហេតុរបស់វា ឬការចូលរួមចំណែករបស់ នួន ជា នៅក្នុងភាពឈឺចាប់របស់ពួកគេ នឹងលែងត្រូវបានទទួលស្គាល់តទៅទៀតហើយ[33]។ វាអាចធ្វើឱ្យកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀង ក្នុងការនាំមកនូវយុត្តិធម៌ដល់ប្រទេសកម្ពុជា ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ទទួលនូវបរាជ័យយ៉ាងច្បាស់ក្រឡែត និងការសម្រេចឱ្យជនដែលទទួលខុសត្រូវខ្ពស់បំផុត ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងទាំងនោះ។

13. វាក្យស័ព្ទនៅក្នុងលិខិតុបករណ៍ដែលគ្រប់គ្រង អ.វ.ត.ក ក៏បានគាំទ្រផងដែរនូវគោលជំហរដែលថា សច្ចធារណ៍នៃនិរទោសចប់នៅពេលដែលពិរុទ្ធភាពមួយត្រូវបានបញ្ជាក់ និងការផ្តន្ទាទោសត្រូវបានដាក់ចូលជាធរមាននៅក្នុងការជំនុំជម្រះមួយ។ អត្ថន័យធម្មតានៃភាសានៃកិច្ចព្រមព្រៀង[34] គាំទ្រដល់វិធីសាស្ត្រនេះ ដូចដែលកិច្ចព្រមព្រៀងចែងថា ជនជាប់ចោទត្រូវ "ត្រូវបានសន្មតថាគ្មានទោសរហូតដល់តុលាការ រកឃើញពិរុទ្ធភាព"[35]។ ស្រដៀងគ្នានេះដែរ វិធាន ២១ នៃវិធានផ្ទៃក្នុង ដែល

---

[32] គោលការណ៍ជាមូលដ្ឋានរបស់ អ.ស.ប, កថាខណ្ឌ ៣(ខ), ៤, ២២(ង), ២៤។ *សូមមើលផងដែរ* របាយការណ៍របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប, UN Doc. E/CN.4/2006/91 (ឆ្នាំ២០០៦), កថាខណ្ឌ ៥៩។

[33] ការិយាល័យគ្រប់គ្រងគ្រឿងញៀន និងការទប់ស្កាត់ឧក្រិដ្ឋកម្មរបស់ អ.ស.ប សៀវភៅស្តីពីយុត្តិធម៌សម្រាប់ជនរងគ្រោះ ឆ្នាំ១៩៩៩ ទំព័រ ៩។

[34] កិច្ចព្រមព្រៀង *មាត្រា ២* ចែងថា (វាត្រូវបកស្រាយតាមអនុសញ្ញាទីក្រុងវីយែន ច្បាប់ស្តីពីសន្ធិសញ្ញា)។ សូមមើល ជាពិសេស អនុសញ្ញាទីក្រុង Vienna Convention ស្តីពីច្បាប់សន្ធិសញ្ញា ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ 1155 UNTS 331, មាត្រា៣១ (ច្បាប់គ្រប់គ្រងបកស្រាយសន្ធិសញ្ញា)។

[35] កិច្ចព្រមព្រៀង មាត្រា ១៣(១)។ *សូមមើលផងដែរ* ICCPR មាត្រា ១៤(២)៖ "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់" មាត្រា ១៤(៥) "ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របតាមច្បាប់"។ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប សេចក្តីអត្ថាធិប្បាយទូទៅលេខ៣២ អំពីមាត្រា ១៤ នៃ ICCPR ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ UN Doc. CCPR/C/GC/32 កថាខណ្ឌ ៣០។

គ្រប់គ្រងលើ "គោលការណ៍សារវ័ន្ត" ចែងថា "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ"[36]។

14. យុត្តិសាស្ត្រគាំទ្រចំណុចនេះបន្ថែមទៀត។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ បានថ្លែងថា "ជាគោលការណ៍សារវ័ន្តនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទ ត្រូវបានសន្មតជាមុនថាគ្មានទោស រហូតដល់តុលាការរកឃើញពិរុទ្ធភាព"[37]។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "វិធាន ២១(ឃ) នៃវិធានផ្ទៃក្នុង ចែងអំពីសិទ្ធិរបស់ជនជាប់ចោទ ដែលគាត់ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គាត់មិនទាន់ត្រូវបានរកឃើញ។ ការសន្មតបែបនេះ ដាក់បន្ទុកលើសហព្រះរាជអាជ្ញាឲ្យបញ្ជាក់នូវពិរុទ្ធភាពរបស់ជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក"[38]។

15. តាមពិត មេធាវីការពារក្តី នួន ជា បានសន្និដ្ឋានពីមុនមកថា "លើកលែងតែនៅពេលដែល [...] អង្គជំនុំជម្រះសាលាដំបូង បានរកឃើញនៅក្នុងសេចក្តីសម្រេចដែលមានសម្អាងហេតុច្បាស់លាស់ និងបានធ្វើឡើងជាលាយល័ក្ខណ៍អក្សរថា មានឧក្រិដ្ឋកម្មធ្ងន់ធ្ងរត្រូវបានប្រព្រឹត្តឡើងមែន ទើបជាការសមស្របដែលអង្គជំនុំជម្រះទទួលយកអង្គហេតុមួយដែលបញ្ជាក់ថា មានព្រឹត្តិការណ៍អកុសលដូច្នេះបានកើតឡើងមែន [...] ដែលនេះ [...] ជាមូលបទមួយដែលយើងត្រូវធ្វើការសន្និដ្ឋានថា ជាការសន្មតថាគ្មានទោស"[39]។ មេធាវី នួន ជា ក៏បានប្រកាសនៅក្នុងអំឡុងនៃសវនាការក្នុងសំណុំរឿង ០០២/០១ ផងដែរថា "នេះជាសិទ្ធិរបស់កូនក្តីខ្លួនដែលត្រូវទទួលបានសិទ្ធិក្នុងការសន្មតថា គ្មានទោស រហូតដល់ពេលតុលាការបានរកឃើញអំពីពិរុទ្ធភាពរបស់គាត់។ វាមិនមែនអាស្រ័យទៅលើថាតើ

---

[36] វិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ ជាងនេះទៀត វិធានរបស់ អ.វ.ត.ក បកស្រាយ "ការឃុំខ្លួនបណ្តោះអាសន្ន" ថាជាការឃុំខ្លួនមុនពេល "សាលក្រមស្ថាពរ" និងធ្វើការបែងចែកដាច់ពីគ្នាយ៉ាងច្បាស់លាស់រវាង "ការឃុំខ្លួនបណ្តោះអាសន្ន" មុនពេលចេញសាលក្រមអង្គជំនុំជម្រះសាលដំបូង និង "ការឃុំខ្លួនជាបណ្តោះអាសន្នជាបន្តទៀត" ក្រោយមកទៀត។ ការណ៍នេះបង្ហាញថាវិធានផ្ទៃក្នុងចាត់ទុកសាលក្រមអង្គជំនុំជម្រះសាលាដំបូងជា "សាលក្រមស្ថាពរ" និងផ្ទុះបញ្ចាំងពីការអនុវត្តរបស់*តុលាការមិនអចិន្ត្រៃយ៍*។ *សូមមើល* វិធាន ៩៩ នៃវិធានផ្ទៃក្នុង និងនិយមន័យនៃពាក្យ "ការឃុំខ្លួនបណ្តោះអាសន្ន" ទំព័រ ៨៥។

[37] ឯកសារ **E176/2** សេចក្តីសម្រេចលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ១៦។

[38] ឯកសារ **E188** សំណុំរឿង ០០១-សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៤។ *សូមមើល* វិធាន ២១(ឃ) នៃវិធានផ្ទៃក្នុង។

[39] ឯកសារ **C11** សវនាការលើបណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អ.ប.ជ, ប្រតិចារឹក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៨, EN 00219554, lines 7-14។

[អ្នកណាផ្សេង] ត្រូវសម្រេចថា [នួន ជា] មានទោសឬក៏អត់នោះទេ គឺអាស្រ័យទៅលើអស់លោកជាចៅក្រមនៅក្នុង [អង្គជំនុំជម្រះសាលាដំបូង] នេះ”[40]។

## III. ការកាត់ទោស នួន ជា មិនគួរទុកជាមោឃៈឡើយ

16. សូម្បីតែសច្ចធារណ៍នៃនិរទោសត្រូវអនុវត្តចំពោះបណ្តឹងសាទុក្ខក្តី ការទុកជាមោឃៈនៃសាលក្រម គឺជាឧបាស្រ័យមិនសមស្របមួយ ដែលគ្មានការគាំទ្រដោយប្រភពច្បាប់យោងណាមួយឡើយ។ ខណៈដែលមេធាវីការពារក្តីថ្លែងថា ការរំលត់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ ធ្វើឲ្យសាលក្រមអង្គជំនុំជម្រះសាលាដំបូងមោឃៈដោយស្វ័យប្រវត្តិក៏ដោយ[41] ពួកគេមិនបានកំណត់អត្តសញ្ញាណដើម្បីគាំទ្រណាមួយដល់ការអះអាងរបស់ពួកគេនៅក្នុងច្បាប់លក្ខន្តិកៈ យុត្តិសាស្ត្រ ឬទម្លាប់នៃការអនុវត្តរបស់ អ.វ.ត.ក របស់កម្ពុជា របស់តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត តុលាការសិទ្ធិមនុស្សតំបន់ ប្រទេសបារាំង ឬប្រព័ន្ធច្បាប់ស៊ីវិលដទៃទៀតឡើយ[42]។ ផ្ទុយទៅវិញ ទាំងច្បាប់កម្ពុជានិងទាំងច្បាប់ អ.វ.ត.ក គឺមិនអនុញ្ញាតឲ្យទុកជាមោឃៈលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងទេ នៅក្នុងកាលៈទេសៈនេះ[43] ហើយវិធាននីតិវិធីអន្តរជាតិដទៃទៀតក៏មិនអនុញ្ញាតឲ្យទុកជាមោឃៈបានដែរនៅ

---

[40] ឯកសារ **E1/24.1** ប្រតិចារឹកនៃសវនាការ ចុះថ្ងៃទី១០ មករា ២០១២, ម៉ោង 09.09.13-09.11.30។ *សូមមើលផងដែរ* ឯកសារ **F16** បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤, កថាខណ្ឌ ៤១ (“មាត្រា ៣៥ថ្មី ចែងថា “ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ”)។ [...] សច្ចធារណ៍នៃនិរទោសមានសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមិនលម្អៀង ដែលមានអានុភាពឯករាជ្យតាមច្បាប់កម្ពុជា និងលិខិតុបករណ៍អន្តរជាតិជាធរមាន។ សារៈសំខាន់នៃសិទ្ធិនេះគឺថាចៅក្រមជំនុំជម្រះលើអង្គហេតុត្រូវតែ “មានគំនិតមិនលម្អៀង” ក្នុងការវាយតម្លៃលើភ័ស្តុតាង”)។

[41] ឯកសារ **F46/2** សំណើ, កថាខណ្ឌ ៣២។ *សូមមើលផងដែរ* កថាខណ្ឌ ១(ខ)(i), ២២-២៣, ២៩(ខ), ៣៣-៣៤, ៨៩(ខ)(i) *និង* ផ្នែក ៤, ចំណងជើង II។

[42] តាមពិត ក្នុងសំណើរបស់ពួកគេ មេធាវីការពារក្តីកំណត់អត្តសញ្ញាណតែយុត្តាធិការ *មួយ* គត់ តាមច្បាប់ក្នុងស្រុក ឬផ្ទុយពីនេះដែលធ្វើឲ្យមោឃៈដល់សាលក្រមសាលាដំបូងនៅក្នុងបរិបទនេះ គឺរបស់សហរដ្ឋ ដែលជាយុត្តាធិការតាមប្រព័ន្ធច្បាប់ខាំម៉ុនឡូ។ *សូមមើល* ឯកសារ **F46/2** សំណើ, កំណត់សម្គាល់ជើងទំព័រ ២៥។ យុត្តាធិការតាមច្បាប់ខាំម៉ុនឡូផ្សេងទៀតដូចជា ប្រទេសអូស្ត្រាលី ចក្រភពអង់គ្លេស និងប្រទេសកាណាដា ជាដើម សុទ្ធតែមិនមោឃភាពឡើយនៅពេលមរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខ ជាក់ស្តែង គឺគេទុកការកាត់ទោសទាំងប៉ុន្មានឲ្យនៅដដែល។ *សូមមើល* សេចក្តីសម្រេចក្នុងរឿងក្តី *Delić*, កំណត់សម្គាល់ជើងទំព័រ ៣៤-៣៥។

[43] *ឯកសារផ្ទុយ ជាឧទាហរណ៍* ឯកសារ **F46/2** សំណើ, កថាខណ្ឌ ២២-២៣។ ផ្ទុយនឹងការអះអាងរបស់មេធាវីការពារក្តី (ឯកសារ **F46/2** សំណើ, កថាខណ្ឌ ២១), នេះមិនមែនជាភ័ស្តុតាង “សំខាន់” នៅក្នុងច្បាប់ទេ ប៉ុន្តែវាគ្រាន់តែឆ្លុះបញ្ចាំងថាសាលក្រមមិនមោឃៈទេនៅក្នុងកាលៈទេសៈដូច្នេះ។ ចំណុចនេះ គឺស្របទៅនឹងយុត្តាធិការនៃច្បាប់ស៊ីវិលដទៃទៀត ដូចជារបស់ប្រទេសបារាំងជាដើម ដែលមានសច្ចធារណ៍នៃនិរទោសលើបណ្តឹងសាទុក្ខ ប៉ុន្តែពុំមានបទប្បញ្ញត្តិលក្ខន្តិកៈដែលអនុញ្ញាតឲ្យមាន

ក្នុងបរិបទនេះ[44]។ ការពិត អ្វីដែលសឹងតែគ្មានការគាំទ្រដល់មោឃភាពបន្តិចសោះនោះ គឺមានករណីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិតែមួយចំណុចប៉ុណ្ណោះ ដែលបានសម្រេចផ្ទុយពីនេះ៖ គឺប្រសិនបើជនដែលត្រូវបានកាត់ទោសហើយ បានស្លាប់នៅក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ នោះសាលក្រមសាលាដំបូងចូលជាស្ថាពរ[45]។

17. ដោយសារតែកង្វះខាតការគាំទ្រដែលពាក់ព័ន្ធសម្រាប់មោឃភាព មេធាវីការពារក្តី វិញ បានថ្លែងទាំងមិនត្រឹមត្រូវចំពោះខ្លឹមសារនៃច្បាប់ក្នុងស្រុក។ ទីមួយ ពួកគេ "ដកស្រង់" មាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង ដូច្នេះថា៖ "ជាការបន្ថែម ខណៈដែលបណ្តឹងសាទុក្ខមិនទាន់ចូលជាស្ថាពរ មូលហេតុណាមួយនៃភាពខុសគ្នានៃការបញ្ចប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌដូចបានរាយឈ្មោះក្នុងមាត្រា ៦ ធ្វើឱ្យមោឃៈដល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង"[46]។ គ្មានសម្រង់ដូច្នេះត្រូវបានគេរកឃើញនៅក្នុងមាត្រានេះទេ[47]។ ទីពីរ មេធាវីការពារក្តីទាមទារថា "នៅក្នុងយុត្តាធិការដែលទទួលស្គាល់សច្ចធារណ៍នៃនិរទោសលើបណ្តឹងសាទុក្ខ នោះអានុភាពផ្លូវច្បាប់ក្នុងការរំលត់កិច្ចដំណើរការនីតិវិធីក៏ *តែងតែ* ធ្វើឱ្យសាលក្រមសាលាដំបូងមោឃៈ[48]។ ពួកគេលើកយោងនូវបទប្បញ្ញត្តិលក្ខន្តិកៈប្រាំមួយពីយុត្តាធិការច្បាប់ស៊ីវិលចំនួនបី[49]។ ក្នុងចំណោមបទប្បញ្ញត្តិ

---

មោឃភាពលើសាលក្រមសាលាដំបូង ក្នុងការឆ្លើយតបទៅនឹងមរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខទេ ដោយសារមរណភាពនៅពេលប្តឹងសាទុក្ខ មិននាំឱ្យមានមោឃភាព។ សូមមើលកំណត់សម្គាល់ជើងទំព័រ ៥២ ខាងក្រោម។

[44] *សូមមើល* កិច្ចព្រមព្រៀង, មាត្រា ១២(១)។ ច្បាប់ អ.វ.ត.ក, មាត្រា ៣៣ថ្មី។

[45] សេចក្តីសម្រេចក្នុងរឿងក្តី *Delić*, កថាខណ្ឌ ១៤-១៦។ សេចក្តីសម្រេចបញ្ចប់ដំណើរការនីតិវិធីក្នុងរឿងក្តី *Popović*, កថាខណ្ឌ ៦។ *សូមមើលផងដែរ* ឯកសារ **F46/3** សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ នួន ជា, ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩, កថាខណ្ឌ ៦ *ពឹងផ្អែកលើ* សេចក្តីសម្រេចក្នុងរឿងក្តី *Delić* ។

[46] ឯកសារ **F46/2** សំណើ, កំណត់សម្គាល់ជើងទំព័រ ២០។ ស្រដៀងគ្នានេះ ឯកសារ **F46/2.1.5** Cass. Crim., ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩១, លេខ 88-81.542 មិនគាំទ្រចំពោះមោឃភាពទេ ប៉ុន្តែគ្រាន់តែបង្ហាញថា មរណភាពរបស់ជនជាប់ចោទនាំឱ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធី និងថាគ្មានអ្វីផ្សេងក្រៅពីនេះទេ។ *សូមមើលកំណត់សំគាល់ជើងទំព័រ ៥២* ខាងក្រោម។

[47] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង, មាត្រា ៦ ("ការចោទប្រកាន់ដោយការដាក់ទោសជាសាធារណៈ គឺត្រូវបានរលត់ត្រឹមមរណភាពរបស់ចុងចោទ ត្រឹមអាជ្ញាយុកាល ត្រឹមការលើកលែងទោសទោស ត្រឹមនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ")។ ប៉ុន្តែ ប្រសិនបើការចោទប្រកាន់ដែលជាលទ្ធផលនាំឱ្យមានការកាត់ទោសនោះ បានលាតត្រដាងឱ្យឃើញអំពីការក្លែងបន្លំនៃសាលក្រម ឬសេចក្តីសម្រេចដែលបានប្រកាសថាការចោទប្រកាន់ជាសាធារណៈត្រូវបានរំលត់ នោះការចោទប្រកាន់អាចនឹងត្រូវបន្ត។ [...]")។

[48] ឯកសារ **F46/2** សំណើ, កថាខណ្ឌ ៣២ (សង្កត់ន័យដើម)។

[49] ឯកសារ **F46/2**, កំណត់សំគាល់ជើងទំព័រ ៣៧ (*សូមមើល* បទប្បញ្ញត្តិលក្ខន្តិកៈជាមូលដ្ឋាន ឬ សេចក្តីសង្ខេបរបស់មេធាវីការពារក្តីផ្ទាល់នៅខាងក្នុងនោះ)។

ទាំងអស់ដែលពួកគេបានលើកយោងនេះ គ្មានមួយណាគាំទ្រដល់មោឃភាពទេ។ ជាចុងក្រោយ មេធាវីការពារក្តីនៅតែទទូចម្តងហើយម្តងទៀតថា នៅក្នុងយុត្តាធិការដែលមានសច្ចធារណ៍នៃនិរទោសលើបណ្តឹងសាទុក្ខ ការរំលត់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខខ្លួនវាផ្ទាល់ ធ្វើឱ្យសាលក្រមសាលាដំបូងមោឃៈ[50]។ ពួកគេលើកយោងដែលគ្មានភ័ស្តុតាងគាំទ្រដល់ការទាមទារទាំងនេះ។

18. ផ្ទុយទៅនឹងការទាមទារមេធាវីការពារក្តី ទម្លាប់នៅក្នុងការអនុវត្តយុត្តាធិការនៃច្បាប់ស៊ីវិលក្នុងស្រុកដែលស៊ីសង្វាក់គ្នាដែលរក្សាទុកសច្ចធារណ៍នៃនិរទោសលើបណ្តឹងសាទុក្ខ ដូចប្រទេសបារាំងជាដើម ដែលច្បាប់កម្ពុជាបានពឹងផ្អែកជាមូលដ្ឋាននោះ[51] គឺថាជនដែលបានកាត់ទោសហើយ បានស្លាប់នៅពេលប្តឹងសាទុក្ខ កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវបានរំលត់ ដោយគ្មានមោឃៈភាព ឬសកម្មភាពបន្ថែមទៀតណាមួយឡើយ[52]។ អភិក្រមដូចគ្នានេះក៏សមស្របសម្រាប់ករណីនៅទីនេះដែរ។

## IV. ដំណោះស្រាយដែលស្នើឡើង

[50] ឯកសារ **F46/2** សំណើ, កថាខណ្ឌ ២៩(ខ), ៣៣-៣៤។

[51] *សូមមើល ជាឧទាហរណ៍* ឯកសារ **E138/1/10/1/5/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០១២, កំណត់សំគាល់ជើងទំព័រ ២០១។ សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, កំណត់សម្គាល់ជើងទំព័រ ៣៩។

[52] <u>សាលាវិនិច្ឆ័យប្រទេសបារាំង:</u> Cass. Crim., ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៨៧, លេខ 86-92.864 (មរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងមោឃភាព បានរំលត់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ (the "*action publique*") និងបានធ្វើឱ្យបណ្តឹងសាទុក្ខក្នុងមោឃភាព លែងជាការចាំបាច់។ Cass. Crim., ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦, លេខ 15-82.742 (កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវបានបញ្ចប់នៅក្រោយមរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងមោឃភាព)។ Cass. Crim., ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦, លេខ 14-84.037 (កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវបានបញ្ចប់ត្រឹមមរណភាពរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងមោឃភាព)។ ឯកសារ **F46/2.1.5** Cass. Crim., ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩១, លេខ 88-81.542 *យោង* នៅក្នុងឯកសារ **F46/2** សំណើ, កំណត់សំគាល់ជើងទំព័រ ២០ (កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវបានបញ្ចប់ ប៉ុន្តែ *សាលាវិនិច្ឆ័យ* ត្រូវបានពិចារណាថា នៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណីរបស់មរណជន)។ *សូមមើលផងដែរ* សាលាឧទ្ធរណ៍ប្រទេសបារាំង: សាលាឧទ្ធរណ៍, Rouen, ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១, លេខ 09/00268។ សាលាឧទ្ធរណ៍, Rouen, ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១, លេខ 11/00086។ សាលាឧទ្ធរណ៍, Douai, ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៧, លេខ 05/02859។ សាលាឧទ្ធរណ៍, Lyon, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩, លេខ 2449/08។ គ្មានសេចក្តីសម្រេចណាមួយនៃសេចក្តីសម្រេចទាំងនេះទុកជាមោឃៈដល់សាលក្រមរបស់តុលាការជាន់ទាបឡើយ។

19. តាមសម្អាងហេតុដែលបានគូសបញ្ជាក់ខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះ ច្រានចោលសំណើសុំរបស់មេធាវីការពារក្តី៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |
| | **លោក William SMITH**<br>សហព្រះរាជអាជ្ញាអន្តរជាតិរងជួស<br>**លោកស្រី Brenda J HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិបម្រុង | | |